**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរអាគារ ចលនទ្រព្យ អចលនទ្រព្យ ឯកសារពាក់ព័ន្ធ និង មន្ត្រីរាជការ ក្របខ័ណ្ឌ នៃសាលាជាតិកសិកម្មកំពង់ចាម និង សាលាជាតិកសិកម្ម ព្រែកលៀប ពីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការផ្ទេរអាគារ ចលនទ្រព្យ អចលនទ្រព្យ និងឯកសារពាក់ព័ន្ធរបស់ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសាធារណការ និង ដឹកជញ្ជូន អតីតក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា អោយមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់ នៃការងារ

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានផ្ទេរការអាគារ ចលនទ្រព្យ អចលនទ្រព្យ ឯកសារពាក់ព័ន្ធ និងមន្ត្រីរាជការក្របខ័ណ្ឌ នៃសាលាជាតិកសិកម្មកំពង់ចាម និង សាលាជាតិកសិកម្មព្រែកលៀប ពីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។-

www.pheakdeylaw.com

**មាត្រា ២.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលខេត្ត–ក្រុង មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច* ✓
- *ឯកសារ–កាលប្បវត្តិ*

www.pheakdeylaw.com